# អនុក្រឹត្យលេខ ១៨ អនក្រ.បក
## ស្តីពី
## ការបង្កើតគណៈកម្មាធិការតំរង់ទិសអន្តរក្រសួង
## ដើម្បីដឹកនាំដំណើរការនៃគំរោងការជំនួយបច្ចេកទេស
## ទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម
## រាជរដ្ឋាភិបាល

====

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១ .-**

បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ តំរង់ទិសអន្តរក្រសួង (Inter-Minisrial Steering Committee) មួយដើម្បីកសាងឯកសារ និងគ្រប់គ្រងនូវសេចក្តីត្រូវការ គំរោងការជំនួយបច្ចេកទេសរបស់បណ្តាក្រសួងទាំងឡាយដែលពាក់ព័ន្ធ សំរាប់បំរើឱ្យផ្នែកពាណិជ្ជកម្ម និងផ្នែកពាក់ព័ន្ធដល់គោលនយោបាយពាណិជ្ជកម្ម ។

**មាត្រា ២ .-**

គណៈកម្មាធិការនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន

២-ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣-ឯកឧត្តម **ម៉ែន សុម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយ និងរដ្ឋាករ អនុប្រធាន

៤-ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៥-ឯកឧត្តម **ហ៊ុល លីម** អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៦-ឯកឧត្តម **សារ៉ាត់ ខាន់** អនុរដ្ឋលេខាធិការ ក្រសួងផែនការ សមាជិក

៧-ឯកឧត្តម **ឡុង ម៉ាន់ហាន** អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

៨-ឯកឧត្តម **ឈុន សារ៉ែត** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

៩-ឯកឧត្តម **គួ លីឌុល្លា** អគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា សមាជិក

១០-លោកជំទាវ **តាល់ ណែរីម** អគ្គនាយកធនាគារជាតិនៃកម្ពុជា សមាជិក

១១-លោក **សុខ សុភ័ក្ត្រ** ប្រធាននាយកដ្ឋាន អាស៊ាននិងអង្គការអន្តរជាតិ សមាជិក

**មាត្រា ៣ .-**

គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ ៖

១- រៀបចំប្រមូលផ្តុំ ចងក្រងឯកសារផ្លូវការនូវរាល់សេចក្តីត្រូវការជំនួយបច្ចេកទេស របស់ក្រសួងនីមួយៗ ដើម្បីសរុបលើកសំណើសុំជំនួយបច្ចេកទេសពីអង្គការសំខាន់ៗទាំងប្រាំមួយ រួមមានអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារពិភពលោក (WB) កម្មវិធី

អភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គសន្និសិទរបស់អង្គការសហប្រជាជាតិស្តីអំពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍ (UNCTAD) អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ក៏ដូចជាសុំជំនួយបច្ចេកទេស ពីបណ្តាប្រទេសរីកចំរើននានាក្នុងពិភពលោកជាលក្ខណៈទ្វេភាគី ។

២- ធ្វើការណែនាំដល់ក្រសួងពាក់ព័ន្ធ ឱ្យរេះកសាងឯកសារគំរោងការជំនួយបច្ចេកទេសសំរាប់រៀបចំគោលនយោបាយ និងអភិវឌ្ឍន៍របស់សាមីក្រសួងនីមួយៗ ដើម្បីយកមកប្រមូលផ្តុំចងក្រងជាឯកសារផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់សុំជំនួយបច្ចេកទេស ។

៣- គណៈកម្មាធិការត្រូវធ្វើការសំរបសំរួលជាប្រចាំ ជាមួយតំណាងអង្គការសំខាន់ៗទាំងប្រាំមួយដូចមានចែងក្នុងចំណុចទី ១ នៃមាត្រា ៣ ដើម្បីបើកកិច្ចប្រជុំតុមូលក្នុងស្រុកមួយរវាងអន្តរក្រសួង សំដៅកសាងឱ្យបានឯកសារ ស្តីពីសេចក្តីត្រូវការជំនួយបច្ចេកទេសពាក់ព័ន្ធនឹងគោលនយោបាយ ពាណិជ្ជកម្មដ៏សុក្រិត្យមួយ ដើម្បីផ្ញើជូនទៅអង្គការទាំងប្រាំមួយ ។

៤- គណៈកម្មាធិការនេះ មានភារកិច្ចត្រួតពិនិត្យមើលនូវជំនួយបច្ចេកទេសដែលទទួលបានដោយក្រសួងនីមួយៗតាមរយៈទ្វេភាគី ឬពហុភាគី ដោយធ្វើយ៉ាងណាជៀសវាងកុំឱ្យមានការទទួលជំនួយនោះ ត្រួតគ្នា ។

៥- តាមដានត្រួតពិនិត្យ និងធ្វើការណែនាំជាប្រចាំនូវការប្រើប្រាស់ជំនួយបច្ចេកទេសរបស់ក្រសួងនីមួយៗ ហើយត្រូវធ្វើសេចក្តីរាយការណ៍ ឱ្យបានទៀងទាត់នូវប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយបច្ចេកទេស ដែលទទួលបានជូនទៅគណៈរដ្ឋមន្ត្រី ។ ក្នុងករណីទំហំការងារនោះហួសសមត្ថកិច្ចរបស់ខ្លួន គណៈកម្មាធិការត្រូវរាយការណ៍ សុំយោបល់ និងសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញមន្ត្រីថ្នាក់ខ្ពស់ពីក្រសួងពាក់ព័ន្ធ ឱ្យចូលរួមប្រជុំគណៈកម្មាធិការ ប្រសិនជាយល់ឃើញថាករណីចាំបាច់ ។

**មាត្រា ៥ .-**

គណៈកម្មាធិការត្រូវជ្រើសតាំង មន្ត្រីជាន់ខ្ពស់របស់ខ្លួនដើម្បីធ្វើជា Focal Point សំរាប់ទំនាក់ទំនងជាមួយអង្គការសំខាន់ៗទាំងប្រាំមួយ ។ គណៈកម្មាធិការអាចប្រើប្រាស់ នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្មធ្វើជាសេនាធិការ និងជាយន្តការសំរាប់ការងារប្រចាំថ្ងៃរបស់ខ្លួន ។

**មាត្រា ៦ .-**

សមាជិកគណៈកម្មាធិការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

**មាត្រា ៧ .-**

គណៈកម្មាធិការមានសិទ្ធិបង្កើតក្រុមការងារតូចៗ ដើម្បីកសាងជំនួយបច្ចេកទេសទៅតាមផ្នែកពាក់ព័ន្ធនីមួយៗ ប្រសិនជាយល់ឃើញថាចាំបាច់ ។ ប្រធាន និង សមាសភាពសមាជិកក្រុមការងារអាស្រ័យលើគណៈកម្មាធិការជាអ្នកសំរេច ។

**មាត្រា ៨ .-**

គណៈកម្មាធិការនេះ ត្រូវមានខ្ទង់ថវិកាដោយឡែកមួយ ដែលជាឧបសម្ព័ន្ធនៃថវិកាក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គទេសាភិបាលធនាគារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**